# ចំណុចពិចារណាមួយចំនួនពីអនាគតកសិកម្មកម្ពុជា

*ដោយ Stephane BOULAKIA បុគ្គលិក CIRAD និង ជាអ្នកជំនួយការបច្ចេកទេសកសិកម្មសំរាប់ MAFF និង គំរោង PADAC*
*ខែ ធ្នូ ឆ្នាំ ២០១០*

អត្ថបទនេះបានសសេរបន្ទាប់ពីរបាយការណ៍សិក្ខាសាលាដែលបានបោះពុម្ពនៅ Cambodge Nouveau លេខ២៩២ ក្នុងបំណង បង្កើត ពន្យល់ និង បញ្ជាក់អោយកាន់តែច្បាស់នូវចំនុចសំខាន់ៗមួយចំនួន ដើម្បីបញ្ចូលទៅក្នុងគំនិតពិចារណាទូទៅមួយ លើអនាគតដែលអាចកើតមានចំពោះកសិកម្មកម្ពុជា ។

ការពិចារណាលើ សេណារីយ៉ូជាទិសដៅ (Perspective scenarios) នៅពេលបច្ចុប្បន្ននេះមានសារៈសំខាន់ណាស់... វាប្រហែលជានឹងហួសពេល បើរង់ចាំដល់ថ្ងៃស្អែក! ដោយសារតែកសិកម្មកម្ពុជាបានឈានដល់ផ្លូវបំបែកថ្មីមួយ ហើយកំពុងប្រឈមនឹងផ្លូវបំបែកផ្សេងៗ ដែលធ្វើអោយការតំរង់ទិសដៅជាយុទ្ធសាស្ត្រមានសារៈសំខាន់បំផុត ព្រោះវាមានឥទ្ធិពលទៅលើ អនាគតកសិករនៅក្នុងពិភពលោក (ដែលមានច្រើនជាង ៧០% នៃចំនួនប្រជាជនទាំងអស់ និង ៩០% នៃចំនួនអ្នកក្រីក្រ) និង ទៅលើ ការការពារបរិស្ថាន ការអភិវឌ្ឍន៍វិស័យដីធ្លី និងក្នុងការអភិវឌ្ឍន៍វិស័យកសិឧស្សាហកម្មអោយទៅជាសរសរគ្រឹះបន្ថែមនៃសេដ្ឋកិច្ចជាតិ ។ ទន្ទឹមនឹងនេះ វាចាំបាច់ផងដែរក្នុងការផ្តល់ហិរិញ្ញវត្ថុ ដើម្បីជាមធ្យោបាយអនុវត្តន៍គោលយោបាយទាំងអស់នេះអោយមានប្រសិទ្ធិភាពនៅកំរិតថ្នាក់ជាតិ ពីព្រោះការផ្សព្វផ្សាយយុទ្ធសាស្ត្រត្រូវការចាំបាច់នូវមធ្យោបាយ!

ការឆ្លើយតបទៅនឹងសំនួរសំខាន់គោលចំនួនពីរខាងក្រោម នឹងនាំអោយមានការបង្កើតទិសដៅថ្មីនៃគោលនយោបាយកសិកម្ម៖

- តើធ្វើដូចម្តេចដើម្បីធានា និង បង្កើនផលិតកម្មស្រូវនៅតំបន់ទំនាបកណ្តាលនៃប្រទេសដែលមានប្រជាជនរស់នៅរហូតដល់ ៧០% នៃចំនួនប្រជាជនសរុប?
- តើធ្វើដូចម្តេចដើម្បីដាក់បញ្ចូលគ្នានូវ ដីបំរុងទុកដ៏ធំធេង នៃតំបន់ខ្ពង់រាបជុំវិញតំបន់ទំនាបកណ្តាល ការរីកលូតលាស់កសិកម្មគ្រួសារដែលមានលក្ខណៈឧស្សាហកម្ម និងប្រកួតប្រជែង និង ការសហការយ៉ាងជិតស្និទ្ធជាមួយវិស័យឧស្សាហកម្ម ដោយក្នុងពេលជាមួយគ្នា រក្សាបាននូវការថែរក្សាអោយមានប្រសិទ្ធិភាព ធនធានធម្មជាតិ (រួមមាន ជីវចំរុះព្រៃឈើ ទឹក និង ដី) ?

## លក្ខណៈពិសេសសំខាន់ៗនៃស្ថានភាពបច្ចុប្បន្នរបស់កសិកម្មគ្រួសារនៅកម្ពុជា

### ផលិតកម្មស្រូវនៅតំបន់ទំនាបកណ្តាល

តាំងពីអតីតកាលរហូតមកដល់បច្ចុប្បន្នកាល កសិកម្មកម្ពុជានៅតែពឹងផ្អែកយ៉ាងខ្លាំង លើដំណាំស្រូវនៅតំបន់ទំនាបដោយពឹងលើទឹកភ្លៀង ជាឧទាហរណ៍មិនមានការគ្រប់គ្រងទឹក ដែលបានពីទឹក ភ្លៀង និងទឹកជំនន់ឡើង ។ កសិកម្មដំណាំស្រូវប្រភេទនេះមាន "ប្រព័ន្ធអេកូកសិកម្ម" សំខាន់ចំនួនពីរ ដែលភាគច្រើន នៅជុំវិញប្រព័ន្ធទន្លេមេគង្គ និងទន្លេសាប ស្ថិតនៅតំបន់ទំនាបកណ្តាលដ៏

ធំធេង ដែលជាបេះដូងនៃ "ដីខ្មែរ" ។ ប្រព័ន្ធអេកូកសិកម្មទាំងពីរនោះរួមៈ ១). ដំណាំស្រូវនៅតំបន់ទំនាបខ្សាច់ភាគខាងលើ ដែលពឹងលើទឹកភ្លៀងទាំងស្រុង និងមិនអាចទទួលទឹកជំនន់ពីទន្លេ (ទឹកមានប្រភពតែ ពីបឹងបួរ អូរ ព្រែក រួចបង្ហូរប្រើប្រាស់ដោយទំនាញផែនដីពីខ្ពស់ទៅទាប) គ្របដណ្តប់លើផ្ទៃដី ១.៥ លានហិតា និង ២). ដំណាំស្រូវលើទំនាបលិចទឹក (Hydromorphic plains) ដែលទទួលទឹកពីទឹកជំនន់ទន្លេ (កំរិតកំពស់ទឹកមិនលើសពី ៧០ ទៅ ៨០ ស.ម) ក្នុងវដ្តនៃការដាំដុះ គ្របដណ្តប់លើផ្ទៃដី ០.៥៥ លានហិតា ។ ដោយសាមញ្ញ កសិករភាគច្រើននៅក្នុងតំបន់អេកូកសិកម្មនីមួយៗ ដាំស្រូវតែមួយដងក្នុងមួយឆ្នាំ ដោយទុកវាលស្រែដែលប្រមូលផលហើយ ជាតំបន់វាលស្មៅសាធារណៈ (វាលស្មៅទំនេរនៃជញ្ជ្រាំងស្រូវ និងស្រូវដំណុះថ្មីពីជញ្ជ្រាំង "កំរាលនៃរដូវក្តៅនៅជនបទ"!) ។

ការដាំដុះស្រូវពីរប្រភេទទៀត អាចជួបប្រទះនៅតំបន់ទំនាបទាប តាមបណ្តោយទន្លេមេគង្គ និងទន្លេសាប ។ តំបន់នេះទទួលទឹកជំនន់មានកំរិតខ្ពស់ ដែលអនុញ្ញាតិអោយដាំបានតែ "ស្រូវដំឡើងទឹក" នៅរដូវវស្សា (ប្រភេទពូជស្រូវដែលអាចលូតបានខ្ពស់រហូត ៤-៥ ម៉ែត្រ) ។ ដំណាំស្រូវប្រភេទនេះ ផ្តល់ផលទាប និងមាននិន្នាការថយចុះ គ្របដណ្តប់លើផ្ទៃដីតែ ០.១ លានហិតា ដោយជំនួសវិញនូវប្រព័ន្ធដាំដុះស្រូវខុសរដូវផ្សេងៗ ដូចជា ស្រូវដាំមុនពេលទឹកជំនន់ (ហៅថា ស្រូវដើមរដូវវស្សា) និង ស្រូវដាំក្រោយពេលទឹកសំរក (ហៅថា ស្រូវប្រដេញទឹក) ។ ដំណាំស្រូវខុសរដូវទាំងពីរនេះ អាចដាំបានដោយសារតែមានប្រព័ន្ធស្រោចស្រពដែលអាចយកទឹកពីទន្លេបាន (ដំណាំស្រូវប្រភេទនេះមានផ្ទៃដីប្រហែល ០.៤៥ លានហិតា) ។

ផលិតផលស្រូវបានកើនឡើងគួរអោយកត់សំគាល់នៅរយៈពេល ១០ឆ្នាំ ចុងក្រោយនេះ ។ ទិន្នផលស្រូវជាមធ្យមបានកើនឡើងពី ១.៩ តោន/ហិតា នៅឆ្នាំ ១៩៩៩ ទៅ ២.៨ តោន/ហិតា នៅឆ្នាំ ២០០៩ ហើយផលិតផលស្រូវសរុបបានកើនឡើងជិតទ្វេរដង ពីជិត ៤.០៥ លានតោន ទៅ ៧.៦ លានតោន ។ កំនើនទ្វេរដងនេះបាននាំអោយមានបរិមាណអង្ករលើស (បរិមាណអង្ករសរុបដកនឹងតំរូវការអង្ករសរុបថ្នាក់ជាតិ) កើនឡើង ៩ដង ពី ០.២៦ ទៅ ២.២៤ លានតោន ។ បរិមាណអង្ករកើនឡើងនេះបានជំរុញការអភិវឌ្ឍន៍ថ្មីៗនៃរោងចក្រកិនស្រូវដើម្បី "កែច្នៃ" "មាសស" ថ្មីនេះ ។ ក៏ប៉ុន្តែការកើនឡើងជាទូទៅនៃផលិតកម្មស្រូវ នៅមិនទាន់មានការធានាអោយគ្រប់គ្រាន់នៅឡើយ និង បានបង្ហាញពីភាពខុសគ្នាខ្លាំងនៃទិន្នផលស្រូវ រវាងតំបន់មួយ និងតំបន់មួយ (តំបន់ខ្លះងាយរងគ្រោះពីអាកាសធាតុ) និង រវាងប្រភេទដំណាំស្រូវ និងប្រភេទកសិករជាអ្នកផលិត... នាំអោយមានសំណួរជាក់លាក់មួយចំនួនដែលគួរតែត្រូវបានផ្តល់ចំលើយអោយបានច្បាស់លាស់ៈ ឧទាហរណ៍ តើនៅកន្លែងណាពិតប្រាកដនៃតំបន់ទំនាប (ដែលងាយធ្វើប្រពលវប្បកម្ម ដោយសារដីមានជីវជាតិ និងអាចស្រោចស្រព) ដែលមានទិន្នផល និងផលិតកម្មកើនឡើង? ហើយ តើកំណើនផលិតភាពនៃដំណាំស្រូវទំនាបភាគខាងលើ មានទំនាក់ទំនងដល់កំរិតណា ជាមួយនឹងដំណើរកើនឡើងនៃការប្រមូលផ្តុំដីធ្លីរបស់ផលិករដែលមានសមត្ថភាពវិនិយោគក្នុងប្រពលវប្បកម្មដំណាំស្រូវ ទោះជាមានគ្រោះថ្នាក់អាកាសធាតុ ដែលកើតមានលើប្រព័ន្ធដាំដុះស្រូវទាំងអស់ខាងលើ ហើយ ការណ៍នេះមានផលអវិជ្ជមានដល់កំរិតណាដល់ប្រជាជនក្រីក្របំផុត?

<u>ដំណាំស្រូវទំនាបកណ្តាលកម្ពុជា និង ព្រៃឈើខ្ពស់រាបកម្ពុជា</u>




ទោះជាការគណនាខាងលើមានចំណុចខ្សោយ ព្រោះតែគ្មានទិន្នន័យជាក់លាក់ យើងអាចប៉ាន់ប្រមាណថានៅតំបន់ទំនាបកណ្តាលមានប្រជាជនប្រហែល ២ លាន គ្រួសាររស់នៅអាស្រ័យលើដីស្រែ ប្រហែល ២.៤ លានហិតា មានន័យថាជាមធ្យម មួយគ្រួសារមានដី ១.២ ហិតា ។ ក៏ប៉ុន្តែជិត ២៥% នៃគ្រួសារទាំងនោះជា "អ្នកគ្មានដីធ្លី" និង ២៥% ទៀតដាំដុះលើផ្ទៃដីតិចជាង ០.៥ ហិតា ។ ដីស្រែតូចៗទាំងនោះ រួមជាមួយនឹងគ្រោះថ្នាក់អាកាសធាតុ ដែលកើតមានលើដំណាំស្រូវទំនាបភាគខាងលើពឹងផ្អែកលើទឹកភ្លៀងទាំងស្រុង (ដោយមិនមានប្រព័ន្ធស្រោចស្រពបន្ថែម) បានកំពុងបន្ថយចំណាប់អារម្មណ៍ និង លទ្ធភាពនានាក្នុងការធ្វើប្រពលវប្បកម្ម តាមរយៈការទិញជីកសិកម្ម ព្រោះការប្រើប្រាស់ជីកសិកម្ម មានហានិភ័យខ្ពស់ខ្លាំងពេកសំរាប់កសិករក្រីក្របំផុត ។ បច្ចេកទេសដាំដុះរបស់កសិករខ្នាតតូចភាគច្រើនមានការវិវឌ្ឍន៍ទៅយ៉ាងយឺត ដែលការប្រើប្រាស់ពលកម្ម នៅមានកំរិតទាបនៅឡើយ (ដើម្បីទុកពេលវេលាធ្វើកិច្ចការផ្សេងៗទៀត) នាំអោយមាន ភាពមានការងារធ្វើមិនពេញលេញនៅកំរិតកសិដ្ឋានគ្រួសារខ្នាតតូច ។

**ចរន្តអភិវឌ្ឍន៍នៅតំបន់ខ្ពង់រាប**

ការងារមិនពេញលេញផ្នែកកសិកម្មនៅជនបទ មិនអាចបំពេញបន្ថែមបានដោយ "ការងារក្រៅកសិកម្ម" ហើយការណ៍នេះបានជំរុញអោយមានចលនាចំណាកស្រុកប្រចាំរដូវ (រឺ អចិន្ត្រៃយ៍) ទៅតំបន់ទីក្រុង តំបន់ព្រំដែន តំបន់នេសាទ និងតំបន់ផ្សេងៗទៀត ។ យោងតាមទិន្នន័យជំរឿនឆ្នាំ ២០០៨ គិតពីឆ្នាំ ២០០៣ ដល់ ២០០៧ មានប្រជាជន ១.៦២ លាននាក់ (១២% នៃប្រជាជានសរុប)

បានផ្លាស់ប្តូរទីលំនៅដែលក្នុងនោះ ០.៥២លាននាក់ បានធ្វើចំណាកស្រុកមករស់នៅទីក្រុងភ្នំពេញ ០.២៦លាននាក់ បានចាកចេញពីទីក្រុងភ្នំពេញ និង ០.៨៤លាននាក់ បានធ្វើចំណាកស្រុកពីខេត្តមួយទៅខេត្តមួយ ។ តាមទិន្នន័យចុងក្រោយបង្ហាញអោយឃើញដែលថា ៨១% នៃចំនួនប្រជាជនចំណាកស្រុកពីខេត្តមួយទៅខេត្តមួយ បានចាកចេញពីខេត្តទាំង៦ ស្ថិតនៅភាគកណ្តាល (ដែលមានដង់ស៊ីតេប្រជាជនខ្ពស់) ដែលក្នុងនោះ ៧០% (០.៥៨ លាននាក់) បានតាំងទីលំនៅនៅខេត្តមួយក្នុងចំណោមខេត្តទាំង១២ នៃភាគ ″ខាងជើងរាងកោង″ (ពីប៉ៃលិន ទៅ មណ្ឌលគិរី) ដែលជាកន្លែងមានដីបំរុងទុកធំ មានសក្តានុពលសំរាប់ការអភិវឌ្ឍន៍វិស័យកសិកម្មនៅតំបន់ ″ខ្ពស់រាបកម្ពុជា″ ។ ការស្វែងរកដីធ្លីថ្មី គឺជាចលករជំរុញអោយមានចំណាកស្រុក ទោះបីជាការរានកាន់កាប់ដីព្រៃជាសកម្មភាពខុសច្បាប់ និងគំរាមកំហែងជាខ្លាំងដល់ព្រៃឈើដែលត្រូវកាប់រានដើម្បីយកដីសំរាប់ដាំជាចំបងដំណាំប្រចាំរដូវសំរាប់លក់ ។ ផែនទីខាងក្រោមបង្ហាញពីស្រុកសំខាន់ៗមួយចំនួនដែលមានចំណាកស្រុកចេញ (ពណ៌បៃតង) និង ចំណាកស្រុកចូល (ពណ៌ក្រហម) ពីឆ្នាំ ២០០៣ និង ២០០៧ ។

<u>តុល្យភាពនៃការធ្វើចំណាកស្រុកកំរិតថ្នាក់ស្រុកពី ២០០៣ ដល់ ២០០៧</u>




ការរីកចំរើនយ៉ាងឆាប់រហ័សនៃការដាំដុះដំណាំប្រចាំរដូវសំរាប់លក់ (ដូចជា ពោត ដំឡូងមី និងសណ្តែកសៀង) សំរាប់ផ្គត់ផ្គង់ទីផ្សារក្នុងតំបន់ (ថៃ វៀតណាម និងចិន) បានជំរុញយ៉ាងខ្លាំងអោយមានចលនានៃការធ្វើចំណាកស្រុក ។ ហេតុដូចនេះដោយមិនមានជំនួយ និងការគាំទ្រពីខាងក្រៅកសិដ្ឋានគ្រួសារកម្ពុជាបានពង្រីកផ្ទៃដីដាំដុះនៅតំបន់ខ្ពង់រាប ៣៥០,០០០ ហិតា ចន្លោះឆ្នាំ ២០០២ និង ២០០៩ (ទិន្នន័យ MAFF) ហើយដីជាង ៦០,០០០ ហិតា បន្ថែមទៀត ត្រូវបានរានធ្វើជាដីកសិកម្មជារាងរាល់ឆ្នាំចាប់ពីឆ្នាំ ២០០៦ ។ ការវិវឌ្ឍន៍ថ្មីៗនេះកើតមានឡើងដំបូងនៅភាគខាងលិចនៃប្រទេស (ដូចជា ប៉ៃលិន និងភាគខាងលិចនៃខេត្តបាត់ដំបង) នៅដើមទសវត្សរ៍ ២០០០ ដោយសារតែដីក្នុងមួយគ្រួសារមានទំហំធំ (ព្រោះជាតំបន់អតីតខ្មែរក្រហម) និងមានតំរូវការទីផ្សារខ្ពស់ពី

ប្រទេសថៃ ។ បន្ទាប់មកតាំងពីពាក់កណ្តាលទស្សវត្សរ៍ ២០០០ ការវិវត្តន៍ទាំងនេះបានរីកសាយទៅតំបន់ខ្ពង់រាបភាគខាងជើងដែលមានប្រជាជនប្រមូលផ្តុំរាយប៉ាយ ។

គួរអោយសោកស្តាយ តំបន់ដែលមានការអភិវឌ្ឍន៍ដំណាំប្រចាំរដូវសំរាប់លក់ ត្រូវបានកាប់រានប្រែក្លាយអោយទៅជាដីកសិកម្មដោយគ្មានផែនការច្បាស់លាស់ (ដោយមើលឃើញថាជាញឹកញាប់តាមរយៈមធ្យោបាយខុសច្បាប់) ហើយ ការដាំដុះដំណាំរបស់កសិករផ្អែកលើការភ្ជួររាស់ និងដំណាំតែមួយមុខដោយមិនមានការប្រើប្រាស់ជី ។ ការដាំដុះបែបនេះធ្វើអោយដីសឹករិចរិល និងខ្សោះជីជាតិយ៉ាងឆាប់រហ័ស ដោយសារតែការហូរច្រោះ ខនិជកម្មនៃសារធាតុសរីរាង្គ និងការថយចុះជីជាតិរ៉ែក្នុងដី ។ នៅប៉ៃលិនទិន្នផលពោតបានថយចុះពី ៧-៨ តោន/ហិតា (លើដីរានថ្មីនៅឆ្នាំ ២០០០) ទៅជួងកាលរហូតដល់ ៣ តោន/ហិតា នៅពេលបច្ចុប្បន្ននេះ នាំអោយមានការបោះបង់ចោលដីចំការ ដែលតាមរយៈការប៉ាន់ស្មានមានចន្លោះពី ១០-១៥% នៅតំបន់ដីរានដំបូងៗគេ ។ ជាលទ្ធផល កសិករមានបំណងធ្វើបំណាកស្រុក និងរានកាន់កាប់ដីថ្មីទៀតនៅតំបន់ផ្សេងៗ ដែលនាំអោយកើតមាន វដ្តនៃការសឹករិចរិលធនធានធម្មជាតិ ។

## ការឆ្ពោះទៅរកវិធីសាស្រ្តថ្មីដើម្បីអភិវឌ្ឍន៍បណ្តុំផលិតកម្មនៃកសិដ្ឋានគ្រួសារ

ការខ្វះខាតនូវការធានាស្របច្បាប់ដើម្បីកាន់កាប់ដីធ្លី ចំណេះដឹងបច្ចេកទេស ឥណទានដែលមានការប្រាក់សមរម្យ បានបង្កជាឧបសគ្គដល់ប្រជាជនចំណាកស្រុកក្នុងការអភិវឌ្ឍន៍កសិកម្មដោយគិតគូរយកចិត្តទុកដាក់ពីបរិស្ថាន អោយមានស្ថេរភាព និរន្តរភាព និងទទួលបានប្រាក់ចំណេញ ។

នៅតំបន់កាប់រានដីព្រៃធ្វើកសិកម្មដំបូងៗគេ គំរោងថ្មីមួយប្រភេទ ដែលអនុវត្តន៍នៅកំរិតបណ្តុំផលិតកម្មសុទ្ធសាធ អាចបង្វែរការអភិវឌ្ឍន៍កន្លងមកអោយទៅរកផ្លូវមួយ ដែលធានាពីនិរន្តរភាព (បច្ចេកទេសនៃកសិកម្មបែបអភិរក្ស ដែលបានពិសោធន៍ និងសាកល្បងនៅកម្ពុជា) មានប្រយោជន៍ច្រើនដល់សង្គម ផ្តល់ប្រាក់ចំណេញខ្ពស់ផ្នែកសេដ្ឋកិច្ច និង មានផលប៉ះពាល់តិចតួចដល់បរិស្ថាន ។

បណ្តុំផលិតកម្មនេះអាចត្រូវបានអនុវត្តន៍នៅតំបន់ដែលមានផ្ទៃដីប្រហែល ៥០,០០០ ហិតា ក្នុងនោះ មួយភាគបួន (២៥%) នឹងត្រូវបានអភិរក្ស ដោយបង្កើតជាបណ្តាញអន្តរតំបន់ជីវចំរុះភ្ជាប់ជាមួយនឹងតំបន់ការពារដែលមានស្រាប់ (បណ្តាញនៃតំបន់ជីវចំរុះ និង ច្រកផ្លូវនៃតំបន់ធម្មជាតិ) ។ ផ្ទៃដីនៅសល់ (៧៥%) នឹងត្រូវបែងចែកអោយទៅកសិករដែលមានសមត្ថភាព និងលទ្ធភាពវិនិយោគកំរិតផ្សេងៗគ្នា ។ ភាពផ្សេងគ្នានៃសមត្ថភាព និងលទ្ធភាពរបស់កសិករ នឹងការពារមិនអោយមានការបង្កើត "កន្លែងបំរុងទុកប្រជាជនក្រីក្រ" ដូចដែលបានកើតមានតាមរយៈការផ្តល់ដីសម្បទានសង្គមកិច្ច តែផ្ទុយទៅវិញ វាបង្កើតអោយមានបណ្តាញចំរុះនៃកសិដ្ឋានគ្រួសារដែលមានការវិវឌ្ឍន៍លឿនខាងសមត្ថភាពផលិតកម្ម និងការបង្កើតថ្មី ។ តំបន់អនុវត្តន៍គំរោងនេះក៏គួរតែបញ្ចូលផងដែរនូវដីសម្បទានសេដ្ឋកិច្ចខ្នាតតូច (ឧទាហរណ៍ពី ៥០០ ទៅធំបំផុត ១០០០ ហិតា) ដើម្បីបង្កើនការផ្ទេរបច្ចេកទេស បច្ចេកវិទ្យា និង បង្កើតការធ្វើកសិកម្មកិច្ចសន្យាជាមួយកសិករដែល

ជាអ្នកផលិតរស់នៅជុំវិញដីសម្បទាន ។ តារាងខាងក្រោមបង្ហាញពីរបៀបនៃការបែងចែកដីធ្លីនៅក្នុងបណ្តុំផលិតកម្ម ។

| "Category" name | Classe | Average size (ha) | Number of households / farms | | | Total area | |
|---|---|---|---|---|---|---|---|
| | | | Local | Migrants / Invest. | Total | Area (ha) | Share (%) |
| 1/ # SLC | 2,5 ha | 2,5 | 3 000 | 2 000 | 5 000 | 12 500 | 25% |
| 2/ Medium Family farms | 2,5 - 6 ha | 4,0 | 3 000 | 1 000 | 4 000 | 16 000 | 32% |
| 3/ Large Family farms | 6 - 15 ha | 8,0 | 300 | 200 | 500 | 4 000 | 8% |
| 4/ Small/ Medium Ag. enterprise | 15 - 100 ha | 25,0 | 25 | 75 | 100 | 2 500 | 5% |
| **Total** | | **3,65** | **6 325** | **3 275** | **9 600** | **35 000** | **70%** |
| ELC | 500 - 1 000 ha | 3 - 4 projects | | | | 2 500 | 5% |

SLC: Social Land Concession (here as farms dispersed in the zone); ELC: Economic Land Concession

រូបភាពខាងក្រោមផ្តល់នូវគំរូនៃការអនុវត្តន៍គំរោងសំរាប់បណ្តុំផលិតកម្ម ដែលមានចំណាប់អារម្មណ៍ (ការទាក់ទាញខ្លាំង) ពីវិស័យកសិឧស្សាហកម្ម ។




គ្រប់ផ្នែកទាំងអស់ (ការបែងចែកដីធ្លី ការការពារបរិស្ថាន និងការអភិវឌ្ឍន៍កសិកម្ម) នៃគំរោងប្រភេទនេះនឹងត្រូវចំណាយ ៦៤ លានដុល្លា សំរាប់ការអនុវត្តន៍គំរោងរយៈពេល ១០ឆ្នាំ ។ ក៏ប៉ុន្តែតំលៃបន្ថែមដែលបង្កើត (តាមរយៈផលិតកម្មកសិកម្ម និងការកែច្នៃផ្នែកកសិឧស្សាហកម្ម)

ក្នុងកំឡុងពេលនេះ នឹងកើនដល់ ១២៥ លានដុល្លា និង តំលៃបន្ថែមប្រចាំឆ្នាំពីឆ្នាំទី១១ នឹងបាន ប្រហែល ៣០ លានដុល្លា ក្នុងមួយឆ្នាំ ។ គ្រួសារចំនួន ៥,០០០ ដែលស្មើប្រជាជនចំនួន ២៥,០០០ នាក់ នឹងចាកផុតពីភាពក្រីក្រ និងដីធម្មជាតិចំនួន ១២,៥០០ ហិតា នឹងត្រូវបានការពាររួមទាំងដី និង ទឹកលើដី ។

**គំរោងដាំដុះលើផ្ទៃដីខ្ពង់រាបចំនួន ៥ លានហិតា សំរាប់កសិដ្ឋានគ្រួសារភាគច្រើន**

បណ្តុំផលិតកម្មទាំងនេះ នឹងធ្វើឡើងជាលក្ខណៈសហការរវាងគំរោងតូចៗ អនុវត្តន៍រួមគ្នា ក្រោមផែនការថ្នាក់ជាតិ ដែលនេះជាមធ្យោបាយយុទ្ធសាស្រ្ត ។ គំរោងតូចៗ ចំនួនប្រហែល ១៤០ សហការគ្នាទៅវិញទៅមក ហើយ អនុវត្តក្នុងរយះពេល ២០-២៥ឆ្នាំ នឹងធ្វើអោយសំរេចគំរោង ផែនការ លើផ្ទៃដីទំហំ ៥ លានហិតា សំរាប់កសិដ្ឋានគ្រួសារដែលផ្សារភ្ជាប់នឹងបណ្តាញនៃកសិដ្ឋាន លក្ខណៈឧស្សាហកម្ម គ្របដណ្តប់លើផ្ទៃដី ៣៦០,០០០ ហិតា និងជាប់ព្រំដែនជាមួយបណ្តាញ តំបន់ការពារធម្មជាតិដែលមានផ្ទៃដី ១.៨ លានហិតា ។

មុនពេលអនុវត្តន៍គំរោងផែនការជាទស្សនៈវិស័យនេះ វាចាំបាច់ណាស់ដែលត្រូវដឹងពីទំហំ ផ្ទៃដីដែលមាន ។ សមីការសមញ្ញមួយខាងក្រោមនេះអាចអោយយើងដឹងពីដីបំរុងទុកនៅកម្ពុជា៖

ផ្ទៃដីព្រៃ = ១៨.១ - ៣.៥ - ៣.៥ - ១.៥ = ៩.៦ លានហិតា

១៨.១ ផ្ទៃដីសរុបនៃប្រទេសគិតជា លានហិតា

៣.៥ ផ្ទៃដីកសិកម្មបច្ចុប្បន្ន

៣.៥ ផ្ទៃដីតំបន់ការពារ

១.៥ ផ្ទៃទឹកអតិបរមានៅរដូវទឹកជំឡើងនៃទន្លេមេគង្គ-ទន្លេសាប (ដោយមានការដាំដុះលើ ផ្ទៃដីមួយចំនួន)

ជាមួយវិធីសាស្រ្តលំអិតជាងខាងលើ តារាងខាងក្រោមសាកល្បងប៉ាន់ប្រមាណពីដីពនរួច "គ្មានព្រៃ" តែមិនទាន់មានសកម្មភាពអភិវឌ្ឍន៍កសិកម្មណាមួយ "គ្មានព្រៃនិងគ្មានសកម្មភាពកសិក ម្ម" នៅខេត្តទាំង ១២ ភាគខាងជើងរាងកោងនៃប្រទេសកម្ពុជា (ប្រមាណ ២/៣ នៃផ្ទៃដីសរុប) ។

| **Province** | ***Total surface (ha)*** | **Forest 2006** | **Forest 2009** | **Non Forest* 2009** | **Agricultural area 2009** | | | | **No Forest/ no Agricult. 2009**** |
|---|---|---|---|---|---|---|---|---|---|
| | | | | | Rice | An. upl. Crops | Peren. crops | **Total** | |
| Banteay Meanc | 614 799 | 99 247 | 71 700 | 537 899 | 214 518 | 37 930 | 4 024 | 256 472 | 281 427 |
| Battambang | 1 187 204 | 534 181 | 496 825 | 685 091 | 260 005 | 198 020 | 8 170 | 466 195 | 218 896 |
| Kampong Char | 948 287 | 154 734 | 139 965 | 773 345 | 211 892 | 91 641 | 14 092 | 317 625 | 455 720 |
| Kampong Thor | 1 244 673 | 619 277 | 603 864 | 623 760 | 208 440 | 11 800 | 7 666 | 227 906 | 395 854 |
| Kratie | 1 197 290 | 948 889 | 939 388 | 217 701 | 44 817 | 18 030 | 3 939 | 66 786 | 150 915 |
| Mondul Kiri | 1 366 881 | 1 258 866 | 1 259 962 | 104 708 | 17 386 | 3 000 | 932 | 21 318 | 83 390 |
| Oddar Meanche | 663 168 | 463 313 | 436 507 | 225 065 | 52 860 | 1 520 | 476 | 54 856 | 170 209 |
| Pailin | 107 681 | 51 458 | 33 973 | 73 708 | 6 223 | 30 565 | 465 | 37 253 | 36 455 |
| Preah Vihear | 1 403 086 | 1 323 275 | 1 311 872 | 90 466 | 39 420 | 21 000 | 926 | 61 346 | 29 120 |
| Ratanak Kiri | 1 178 453 | 966 965 | 950 930 | 218 049 | 25 664 | 8 276 | 105 | 34 045 | 184 004 |
| Siem Reap | 1 054 442 | 473 632 | 438 615 | 604 751 | 194 500 | 2 200 | 6 615 | 203 315 | 401 436 |
| Stung Treng | 1 201 656 | 1 063 859 | 1 054 790 | 111 112 | 23 607 | 3 706 | 1 920 | 29 233 | 81 879 |
| ***Total*** | ***12 167 620*** | ***7 957 696*** | ***7 738 391*** | ***4 265 653*** | ***1 299 332*** | ***427 688*** | ***49 330*** | ***1 776 350*** | ***2 489 303*** |

* Excluded water surface (lack, river…)

** Included the land for infrastructure and cities which is around 200,000 hectares for the 12 provinces

(The forest area in 2009 is estimated on the basis of the forest area in 2006 and of extrapolating the growth rates of deforestation between 2002 and 2006 for the period 2007-2009)
Source: MAFF (2009)

មួយភាគធំនៃផ្ទៃដីទំហំ ៥.៤ លានហិតា នឹងត្រូវបានអភិវឌ្ឍន៍នៅខេត្តទាំង១២ ដែលអាចគ្របដណ្តប់លើផ្ទៃដីទំហំ ២.៣ លានហិតា នៃតំបន់មិនទាន់អភិវឌ្ឍន៍ ជាមួយនឹង ០.៥ លានហិតា នៃផ្ទៃដីកសិកម្មដែលមានស្រាប់ ។ ដូច្នេះវាចាំបាច់ត្រូវ "រានដីព្រៃថ្មី" ចំនួន ២.៥ លានហិតា (ដីព្រៃនៅសល់ប្រហែល ៤០% នៃផ្ទៃដីសរុប) ក្នុងរយៈពេល ២៥ឆ្នាំ ជាមួយនឹងអត្រារានដីដែលធ្លាប់មានកន្លងមក ។ ក៏ប៉ុន្តែការរានដីព្រៃថ្មីនេះ ធ្វើឡើងទៅតាមគំរោងផែងការច្បាស់លាស់ និងស្ថិតក្រោមការសំរបសំរួលសមស្របមួយជាមួយនឹងការលើកកម្ពស់ និង ពង្រឹងការការពារ និងថែរក្សាធនធានធម្មជាតិ ។

ផ្អែកលើការវាយតំលៃនៃការចំណាយសំរាប់គំរោងមួយ ការចំណាយសរុបនៃគំរោងខាងលើនឹងត្រូវជា ៩.១ កោដិដុល្លា (៤.៣ កោដិដុល្លា សំរាប់គាំទ្រផលិតកម្មកសិកម្ម ៤.១ កោដិដុល្លា សំរាប់ការគ្រប់គ្រង និងបែងចែកដីធ្លី និង ០.៧ កោដិដុល្លា សំរាប់ការថែរក្សា និងស្តារឡើងវិញតំបន់ការពារ)... នេះជាការចំណាយសរុបទាបល្មម បើប្រៀបធៀបនឹងចំនួនទឹកប្រាក់សរុបដែលប្រទេសកម្ពុជា ទទួលបានពីម្ចាស់ជំនួយសំរាប់គាំទ្រការអភិវឌ្ឍន៍សាធារណៈ (ប្រហែល ១ កោដិដុល្លា ក្នុងមួយឆ្នាំ) ។

ការបង្កើតតំលៃបន្ថែមក្នុងកំឡុងពេល ២៥ឆ្នាំ នេះនឹងមាន ៣៥ កោដិដុល្លា និង តំលៃបន្ថែមប្រចាំឆ្នាំ នៅដំណាក់កាលបញ្ចប់នៃការអនុវត្តន៍គំរោង នឹងមានខ្ពស់ជាង ៤ កោដិដុល្លា ក្នុងមួយឆ្នាំ (ចំនួននេះមិនទាន់គិតបញ្ចូលនៅឡើយតំលៃបានមកពីសេវាកម្មបរិស្ថាន) ។ ប្រជាជន ៦.៩ លាននាក់ (ប្រហែល ១/៣ នៃប្រជាជនសរុបនៅឆ្នាំ ២០៣៥) នឹងចូលរួម រឺ ពាក់ពាន់នឹងគំរោងនេះ ហើយប្រជាជនច្រើនជាង ៣.៥ លាននាក់ (៧០០,០០០ គ្រួសារ) អាចចាកផុតពីភាពក្រីក្រ ។ ការធ្វើចំណាកស្រុករបស់ប្រជាជនទៅតំបន់ខ្ពង់រាប នឹងអនុញ្ញាតិអោយមានស្ថេរភាព នូវការថយចុះនៃទំហំដីស្រែក្នុងមួយគ្រួសារ នៅតំបន់ទំនាបកណ្តាល និង បើកច្រកអោយមានការប្រមូល ផ្តុំក្បាលដីស្រែតូចៗ អោយទៅជាធំៗ ដែលនេះជាតំរូវការចាំបាច់ជាបឋម ក្នុងការធ្វើប្រពលវប្បកម្មដំណាំស្រូវ (ដូចជា៖ ប្រព័ន្ធស្រោចស្រព ប្រព័ន្ធដាំដុះដោយមិនបាច់ភ្ជួរផ្អែកលើសារធាតុគំរបដី) ។

**ជាការសន្និដ្ឋាន...**

ដីបំរុងទុកនៅកម្ពុជា ដែលស្ថិតក្នុងចំណោមតំបន់ចុងក្រោយ មានសក្តានុពលផ្នែកកសិកម្មនៅតំបន់អាស៊ីអាគ្នេយ៍ ទាក់ទាញយ៉ាងខ្លាំងតួអង្គថ្នាក់ជាតិ និងអន្តរជាតិផ្សេងៗ ដែលមានចំណាប់អារម្មណ៍ខុសៗគ្នា ។ ដីធ្លីគឺជាមូលហេតុចំបងនៃជំលោះសង្គមដ៏ស្មុកស្មាញបច្ចុប្បន្ននេះ ដែលករណីនេះធ្លាប់កើតមានឡើងនៅទស្សវត្សទី ៦០ ... នៅផ្លូវបំបែកនៃការអភិវឌ្ឍន៍កម្ពុជា ការទាញយកប្រយោជន៍តាមមធ្យោបាយដ៏ត្រឹមត្រូវពីធនធានចុងក្រោយនេះ ត្រូវបានជាប់គាំង ខណៈពេលដែលកំលាំងទឹកចិត្ត និងភាពតានតឹងបានកើនឡើង ។ ក្នុងពេលជាមួយគ្នានេះ ធនធានធម្មជាតិ (ដូចជា៖ ជីវចំរុះព្រៃឈើ និង ដី) បានកំពុងសឹករិចរិល ដោយមិនមានគំរោងការអភិវឌ្ឍន៍ណាមួយលើដីរានហើយ អោយមាននិរន្តភាព និងមានប្រសិទ្ធិភាពផ្នែកសង្គម និងសេដ្ឋកិច្ច ។

បច្ចុប្បន្ននេះ ការបែងចែកដីធ្លីដែលជា "ដីឯកជនរបស់រដ្ឋ" អាចធ្វើឡើងស្របច្បាប់តាមរយៈវិធីសាស្ត្រពីរគត់៖

- ដីសម្បទានសេដ្ឋកិច្ចផ្តល់អោយទៅក្រុមហ៊ុនឯកជន ដើម្បីអភិវឌ្ឍន៍ដំណាំឧស្សាហកម្ម (ជាទូទៅ ដំណាំតែមួយមុខ) លើផ្ទៃដីអតិបរមាទំហំ ១០,០០០ ហិតា ។ វិធីសាស្ត្រផ្តល់ដីសម្បទានបែបនេះ ប្រឈមយ៉ាងធ្ងន់ធ្ងរនឹងវិវាទជាច្រើន រវាងម្ចាស់ដីសម្បទាន និងប្រជាជនមូលដ្ឋានដែលបានកាន់កាប់ភាគណាមួយនៃដីសម្បទាន (តាមមធ្យោបាយកាន់កាប់ពីអតីតកាល រឺ តាមមធ្យោបាយនាពេលថ្មីៗ) ។ ចំពោះដំណោះស្រាយសំរាប់វិវាទខាងលើ ភាពចាំបាច់ក្នុងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសំរាប់ទាញប្រយោជន៍ពី ដីសម្បទានសេដ្ឋកិច្ច (ដូចជា ផ្លូវលំ ផ្លូវថ្នល់ អគ្គិសនី) សេវាសាធារណៈ (មន្ទីរពេទ្យ សាលារៀន) និង ថ្លៃដើមផលិតកម្ម និងការចំណាយសំរាប់លក់ផលិតផលខ្ពស់ (តំបន់ដាច់ស្រយាល ការដឹកជញ្ជូន និងពន្ធគយ) កាន់បន្ថយយ៉ាងច្រើន លទ្ធភាពចំណេញផ្នែកសេដ្ឋកិច្ចនៃការផ្តល់ដីសម្បទានសេដ្ឋកិច្ច នៅក្នុងបរិបទប្រកួតប្រជែងផ្នែកសេដ្ឋកិច្ចអន្តរជាតិ ។ បច្ចុប្បន្ននេះ មានដីសម្បទានសេដ្ឋកិច្ច ប្រហែល ១.៣ លានហិតា ដែលក្នុងនោះប្រហែល ៧០% មានសក្តានុពលសំរាប់ការអភិវឌ្ឍន៍កសិកម្ម (៩០០,០០០ ហិតា) ហើយ តិចជាង ៨០,០០០ ហិតា បានកំពុងបង្កើតតំលៃកសិកម្មយ៉ាងមានប្រសិទ្ធិភាព ។
- ដីសម្បទានសង្គមកិច្ចជាមធ្យោបាយបែងចែកដីធ្លី (តូចជាង ២.៥ ហិតា ក្នុងមួយគ្រួសារ) សំរាប់គ្រួសារក្រីក្រនៅជនបទ ដែលជាទូទៅជា "អ្នកគ្មានដី" ។ គំរោងសាកល្បងដំបូងនៃការផ្តល់ដីសម្បទានសង្គមកិច្ច បានអនុវត្តន៍ក្នុងរយៈពេលខ្លី (ជាមួយគ្រួសារទទួលផលប្រយោជន៍ចំនួន ១៦,៥០០) ក៏មិនបានទទួលលទ្ធផលគួរអោយពេញចិត្ត ។ វាបាននាំអោយមានការបង្កើត "ការបំរុងទុកអ្នកផលិតក្រីក្រ" ជាទូទៅនៅតំបន់ដាច់ស្រយាល ដោយគ្មានការគាំទ្រពេញលេញ និងយូរអង្វែង (ដូចជាៈ ការរៀបចំបង្កើត ក្រុមរឺសមាគមកសិករ ការផ្តល់ឥណទាន និងការស្វែងរកទីផ្សារជាដើម) អ្នកទាំងនោះ មិនអាចទាញយកប្រយោជន៍អោយបានត្រឹមត្រូវពីដីសម្បទានសង្គមកិច្ចដែលទទួលបាន ។ តាមរយៈលទ្ធផលនេះ អ្នកបង្កើតគោលនយោបាយភាគច្រើនយល់ឃើញថាការផ្តល់ដីសម្បទានសង្គមកិច្ចជាមធ្យោបាយអភិវឌ្ឍន៍ដីធ្លីមិនពេញលេញ ។

គោលនយោបាយថ្មី ដែលប្រែក្លាយវិវាទបច្ចុប្បន្នអោយទៅជា កំលាំងផលិតរួមដែលយើងអាចស្រមៃឃើញ... វាគួរដំណើរការតាមទិសដៅថ្មីដូចខាងក្រោម៖

- ការបែងចែកដីធ្លីទៅអោយក្រុមកសិដ្ឋានគ្រួសារ ដែលមានចំរុះប្រភេទពីអ្នកផលិតខ្នាតតូច ទៅ សហគ្រាសកសិកម្មខ្នាតតូច និងមធ្យម (តំរូវអោយមានការកែប្រែច្បាប់ដីធ្លីបន្តិចបន្តួច) រួមជាមួយនឹងបណ្តាញកសិករគ្រួសារ និងចំការដាំណាំឧស្សាហកម្ម ដែលមានផ្ទៃដីតូចជាងផ្ទៃដីសម្បទានសេដ្ឋកិច្ចបច្ចុប្បន្ន ។ ក្រុមអ្នកផលិតដូចនេះនឹង ធ្វើអោយមានការវិវឌ្ឍន៍កាន់តែឆាប់រហ័ស (កម្មសិទ្ធិដីធ្លី មិនទទួលឥទ្ធិពលពីទស្សនៈនៃ

ការទិញទុកដើម្បីលក់យកចំណេញ) ងាយស្រួលបត់បែន និង ងាយសំរបនឹងការប្រែប្រួលអាកាសធាតុដែលនឹងកើតមានឡើង និងការប្រែប្រួលទីផ្សារ ។

- ការបង្កើត ˝ទន់ដ៏ច្រើន˝ ជាតិ និងអន្តរជាតិ ពីសេដ្ឋកិច្ចនៃចំការឧស្សាហកម្ម ដែលឆ្ពោះទៅរកការកែច្នៃផលិតផលកសិកម្មរបស់កសិដ្ឋានគ្រួសារ ។

ដូច្នេះមានការវិវឌ្ឍន៍ពីរ ទៅថ្ងៃអនាគត... មួយគឺទ្រព្យសម្បត្តិដីធ្លីដ៏ធំធេង ចំការឧស្សាហកម្មធំៗ និង ទីក្រុងខ្ទមរខេតរខាក (ឧទាហរណ៍ នៅកោះ ឥណ្ឌូនេស៊ី និង ហ្វីលីពីន) និង មួយទៀត ការវិវត្តន៍នៃកសិដ្ឋានគ្រួសារផ្អែកលើការកែច្នៃផ្អែកឧស្សាហកម្ម... (ឧទាហរណ៍ នៅប្រទេស ថៃ និង វៀតណាម) ។ តើមានជំរើសណាផ្សេងដែលរឺទេ?